# ការពង្រីកប្រភពកំណើន សេដ្ឋកិច្ចកម្ពុជា: តួនាទីនៃការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងឧត្តមសិក្សា[១]

វេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា

សង្ខេបគោលនយោបាយ 2013, លេខ 01 *

## សេចក្តីផ្តើម

សេដ្ឋកិច្ចកម្ពុជាមានកំណើនយ៉ាងលឿន និងឈានទៅធ្វើឧស្សាហូនីយកម្មកាន់តែខ្លាំងឡើង។ អត្រាកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំមានជាង ៨% តាំងពីឆ្នាំ២០០០ មក (World Bank 2012) ហើយតាមការព្យាករណ៍ នឹងមានកម្រិតប្រហែល ៧% សម្រាប់ប្រាំឆ្នាំខាងមុខទៀត (Huot 2013)។ វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម ជាកម្លាំងជំរុញដ៏សំខាន់នៃកំណើនសេដ្ឋកិច្ច។ ចំណែកនៃវិស័យឧស្សាហកម្មនៅក្នុង ផលិតផលក្នុងស្រុកសរុប (ផសស) បានកើនពី ២២,៤% នៅឆ្នាំ២០០៨ ដល់ ២៦,៤% នៅឆ្នាំ២០១០ (ក្នុងនេះ វិស័យកាត់ដេរ និងវាយនភ័ណ្ឌ រួមចំណែក ១២%) ហើយចំណែកនៃវិស័យសេវាកម្ម កើនពី ៣៨,៨% ដល់ ៤០,៦% (ក្នុងនេះ សណ្ឋាគារ និងភោជនីយដ្ឋាន រួមចំណែក ៤,៤%) (NIS 2008; Hing *et al.* 2012)។ ចំណែកវិស័យកសិកម្មក្នុង ផសស ធ្លាក់ចុះពី ៣៨,៨%នៅឆ្នាំ២០០៨ មក ៣៣% នៅឆ្នាំ២០១០។ កម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្មបានកើនពី ៨,៥% នៃកម្លាំងពលកម្មសរុបនៅឆ្នាំ២០០៨ ដល់ ១២% នៅឆ្នាំ២០១០ ហើយក្នុងវិស័យសេវាកម្ម បានកើនពី ១៩,២% ដល់ ២០% ប៉ុន្តែក្នុងវិស័យកសិកម្ម គឺបានថយចុះពី ៧៣,២% មក ៦៨% ក្នុងអំឡុងពេលនោះ។ ដោយសារមានកំណើនសេដ្ឋកិច្ច អត្រាភាពក្រីក្រធ្លាក់ចុះពី ២២,៨៩% នៅឆ្នាំ២០០៩ មក ២១,១% នៅឆ្នាំ២០១០ និង ១៩,៨% នៅឆ្នាំ២០១១ (MoP 2013)។

អត្ថបទសង្ខេបគោលនយោបាយនេះ មានគោលដៅពិភាក្សាពីការបណ្តុះបណ្តាល និងទំនាក់ទំនងនៃឧត្តមសិក្សា និងការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទៅនឹង ការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា ដោយផ្តោតជាពិសេសលើ ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងបម្រែបម្រួលនៃតម្រូវការធនធានមនុស្ស និងកម្រិតដែលឧត្តមសិក្សា និងការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ បានឆ្លើយតបនឹងតម្រូវការនេះ។ អត្ថបទក៏មានផ្តល់មតិខាងគោលនយោបាយមួយចំនួនដែរ ដើម្បីផ្សារភ្ជាប់តម្រូវការ ទៅនឹងការផ្គត់ផ្គង់។

## តើសេដ្ឋកិច្ចត្រូវការអ្វី?

តម្រូវការពលករក្នុងវិស័យឧស្សាហកម្មនិងសេវាកម្មកំពុងកើនឡើងជាពិសេស ពលករអ្នកមានជំនាញ និងបច្ចេកទេស។ ពីឆ្នាំ២០០៨ ដល់២០១០ប្រមាណ៨៧%នៃតម្រូវការបុគ្គលិកក្នុងគម្រោងវិនិយោគទទួលបានការអនុម័តពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គឺជា ពលករប្រើកម្លាំងដែលមានជំនាញនិងមិនមានជំនាញ (CDC 2011, cited in D'Amico 2012)។ មានតែវិស័យសេវាកម្មមួយប៉ុណ្ណោះដែលត្រូវការបុគ្គលិកមួយចំនួនតូចផ្នែកគណនេយ្យ គ្រប់គ្រង ច្បាប់ និងសេដ្ឋកិច្ច។ ជាលទ្ធផល គ្រឹះស្ថានឧត្តមសិក្សា បានបណ្តុះបណ្តាលនិស្សិតលើសពីតម្រូវការនៃទីផ្សារការងារ។ គេបានគន់គូរថា ក្នុងឆ្នាំ២០១២ ទីផ្សារពលកម្មត្រូវការនូវនិស្សិតបញ្ចប់ការសិក្សាប្រហែល ១៦.០០០នាក់ ប៉ុន្តែ គ្រឹះស្ថានឧត្តមសិក្សាបណ្តុះបណ្តាល បានដល់ប្រហែល ២៩.០០០នាក់ ហើយតួលេខនេះអាចឡើងដល់ ២២.០០០នាក់ ធៀបនឹងនិស្សិតបញ្ចប់ការសិក្សា ៧០.០០០នាក់ នៅឆ្នាំ២០១៤ (HRINC 2010, cited in D'Amico 2012) (រូបភាព១)។ ក្នុងចំណោមនិស្សិតបញ្ចប់សាកលវិទ្យាល័យនៅឆ្នាំ២០០៨ មានប្រមាណ ១០% ប៉ុណ្ណោះដែលរកការងារធ្វើបានក្នុងឆ្នាំនោះ (CAMFEBA 2008)។ ទីផ្សារពលកម្មត្រូវការច្រើនជាងនូវ ជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ។

ការចុះឈ្មោះចូលរៀនថ្នាក់ឧត្តមសិក្សារបស់និស្សិត លើមុខវិជ្ជាវិទ្យាសាស្ត្រនិងវិស្វកម្ម ផលិតកម្មនិងសំណង់ សុខភាពនិងសុខុមាលភាព និងកសិកម្ម គឺមានកម្រិតទាប បើធៀបនឹងប្រទេសឯទៀតក្នុងតំបន់អាស៊ីអាគ្នេយ៍ (តារាង១)។ កម្លាំងពលកម្មមានការបណ្តុះបណ្តាលផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈក៏មានតិចណាស់ដែរ បើធៀបនឹងប្រទេសឯទៀតក្នុងតំបន់ ដែលបង្ហាញពីភាពមិនស៊ីគ្នារវាងតម្រូវការនូវសមត្ថភាពជំនាញឯកទេស នឹងអ្នកមានជំនាញបែបនេះ។ ម្យ៉ាងទៀត ទោះបីជាកសិកម្មរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញកំណើនផលិតផលក្នុងស្រុកសរុប (ផសស) និងជួយស្រូបយកបានដល់ជាង ៧០% នៃកម្លាំងពលកម្មសរុបក្តី ក៏និស្សិតចុះឈ្មោះចូលរៀនខាងកសិកម្មនៅតាមសាកលវិទ្យាល័យ មានតិចទាក់ណាស់ មិនដល់ ៤% នៃចំនួននិស្សិតចុះឈ្មោះចូលរៀនសរុបនៅឧត្តមសិក្សានោះទេ (Mak 2012)។

ជំនាញមិនស៊ីគ្នានឹងតម្រូវការ នាំឲ្យមានអ្នកដាក់ពាក្យសុំតិចនាក់ដើម្បីចូលធ្វើការក្នុងមុខតំណែងផ្សេងៗ។ យោងតាមទីភ្នាក់ងារជាតិមុខរបរនិងការងារ នៅឆ្នាំ២០១០-១២ ប្រទេសកម្ពុជាមានដល់ ៣៥.៩៧៦ការងារនៅទំនេរ ប៉ុន្តែមានអ្នកដាក់ពាក្យសុំធ្វើការតែ ៦.៨៦០នាក់ប៉ុណ្ណោះ (១៩.០៦%) (NEA 2012, cited in Heng 2013)។ ក្នុងអំឡុងពេលដដែលនោះ រយៈពេលជ្រើសរើសបុគ្គលិកជំនាញដើម្បីបំពេញមុខតំណែងនៅទំនេរ បានកើនឡើងពី ៤,២ ទៅ ១១,៧សប្តាហ៍។ នៅចុងទសវត្សរ៍២០០០ អង្កេតមួយអំពីតម្រូវការរបស់និយោជក និងជំនាញរបស់យុវជន បានបង្ហាញថា យុវជនហួត

---

[១] អត្ថបទនេះរៀបរៀងឡើងដោយ **បណ្ឌិត អ៊ុន លាង** និង **បណ្ឌិត ជួន រម្យរាស៊ី** ជាអ្នកសម្របសម្រួលក្រុមស្រាវជ្រាវផ្នែកអប់រំ និង **បណ្ឌិត ជិន ច័ន្ទរិទ្ធ** ជាសមាជិកគណៈកម្មាធិការដឹកនាំការងារ នៃវេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា។ អត្ថបទសង្ខេបគោលនយោបាយនេះ ផ្អែកលើការពិភាក្សាគោលនយោបាយតុមូល និងសិក្ខាសាលាស្រាវជ្រាវឆ្នាំ ២០១២ រៀបចំឡើងដោយ ក្រុមស្រាវជ្រាវផ្នែកអប់រំ និងសម្របសម្រួលដោយ **សាកលវិទ្យាល័យភូមិន្ទភ្នំពេញ** (RUPP) ដែលជាដៃគូមួយនៅក្នុង វេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា ។

* ចេញផ្សាយដោយ វេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា

រូបភាព ១៖ តម្រូវការ និងការបណ្តុះបណ្តាលនិស្សិតឧត្តមសិក្សា
នៅកម្ពុជា ពីឆ្នាំ២០០៩ ដល់ ២០១៤




ប្រភព៖ HRINC (2010) cited in D'Amico (2012)

ដល់ ៧៦%មិនមានជំនាញដែលនិយោជកស្វែងរកនោះទេ (World Bank 2009; Chan 2008)។

សព្វថ្ងៃនេះ ក្តីបារម្ភមានកាន់តែច្រើនឡើង មិនត្រឹមតែអំពីបញ្ហាសមត្ថភាពជំនាញមិនសមស្របនឹងតម្រូវការការងារប៉ុណ្ណោះទេ ប៉ុន្តែអំពីបញ្ហាការអប់រំមានគុណភាពទាបថែមទៀត។ ការចុះឈ្មោះចូលរៀនជំនាញគ្រប់គ្រង និងពាណិជ្ជកម្មមានយ៉ាងច្រើនក៏ពិតមែន ប៉ុន្តែកម្ពុជានៅតែខ្វះខាតខ្លាំងនូវពលករក្នុងស្រុក សម្រាប់បម្រើការក្នុងមុខតំណែងផ្នែកគ្រប់គ្រង ផ្នែកគ្រប់គ្រង/ត្រួតពិនិត្យកម្រិតមធ្យម និងផ្នែកជំនាញវិជ្ជាជីវៈផ្សេងទៀត (HR Inc. Cambodia & Garment Industry Productivity Center 2008)។ ក្នុងវិស័យសំណង់ ពលករកម្ពុជាធ្វើបានតែការងារប្រើកម្លាំង និងការងារមានជំនាញទាប រីឯអ្នកមានជំនាញខ្ពស់ៗ និងវិស្វករភាគច្រើន សុទ្ធតែជាជនបរទេស។ ក្នុងវិស័យកាត់ដេរ ជាពិសេសផ្នែកផលិតកម្ម ជនបរទេសបម្រើការទាំងអស់ក្នុងមុខតំណែងកំពូលគេទាំងពីរ និងបម្រើការក្នុង ៥០% នៃមុខតំណែងកំពូលគេទាំងបួន (Un 2012) ។

## តើគ្រឹះស្ថានឧត្តមសិក្សាបណ្តុះបណ្តាលអ្វីខ្លះ?

ប្រព័ន្ធអប់រំនៅកម្ពុជា ដើមឡើយមិនបានផ្តល់អាទិភាពលើការអប់រំថ្នាក់ឧត្តមសិក្សាទេ។ តាំងពីដើមទសវត្សរ៍១៩៩០ មក កម្ពុជាបានចំណាយជាមធ្យម ២%នៃចំណាយសរុប ទៅលើការអប់រំថ្នាក់ឧត្តមសិក្សា។ នៅចុងទសវត្សរ៍១៩៩០ ឯកជនភាវូបនីយកម្មបានចាប់ផ្តើមឡើង ដើម្បីឆ្លើយតបទៅនឹងកំណើនចំនួនសិស្សបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ។ តាំងពីពេលនោះមក គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនកើនឡើងយ៉ាងខ្លាំង ពីត្រឹម ១៨គ្រឹះស្ថានក្នុងឆ្នាំ១៩៩៧ ដល់ ៩៧ គ្រឹះស្ថានក្នុងឆ្នាំ២០១១ (Mak 2012)។ និស្សិតថ្នាក់ឧត្តមសិក្សាបានកើនឡើងពី ១០.០០០នាក់នៅដើមទសវត្សរ៍១៩៩០ ដល់ជាង ២២០.០០០នាក់ក្នុងឆ្នាំ២០១១។

ដូចបានរៀបរាប់ខាងលើ គ្រឹះស្ថានឧត្តមសិក្សាមិនបានផ្តល់កម្មវិធីសិក្សាប្រកបដោយគុណភាព និងស្របតាមតម្រូវការនៃទីផ្សារការងារ និងសេដ្ឋកិច្ចឡើយ ដោយសារកត្តាមួយចំនួន។ ទី១ ក្រៅពីការឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុមិនបានគ្រប់គ្រាន់ ប្រទេសកម្ពុជាមិនទាន់មានគោលនយោបាយស៊ីចង្វាក់គ្នាល្អទេ។ ពង្រាងគោលនយោបាយថ្មីៗស្តីពីចក្ខុវិស័យនៃឧត្តមសិក្សាឆ្នាំ២០៣០ ដែលឆ្លើយតបបានកាន់តែប្រសើរ ទៅនឹងបរិបទអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និងតម្រូវការទីផ្សារ កំពុងស្ថិតក្នុងដំណើរការអនុម័ត (Mak 2012: 31)។

ទី២ ឧត្តមសិក្សាផ្តោតលើការពង្រីកវិសាលភាព និងបរិមាណ ដោយមិនសូវផ្តោតលើការពង្រឹងគុណភាព និងតម្រូវការទីផ្សារការងារនោះទេ។ ឧទាហរណ៍ ក្នុងផែនការអប់រំឆ្នាំ២០០៥-២០០៩ មានកំណត់ច្បាស់ពី គោលដៅបង្កើនចំនួននិស្សិតចុះឈ្មោះចូលរៀនពី ២៥.០០០នាក់នៅឆ្នាំសិក្សា២០០៤-០៥ ដល់ ៩០.០០០នាក់នៅឆ្នាំ ២០១០ ប៉ុន្តែជាក់ស្តែងចំនួននិស្សិតបានកើនដល់ជាង ២០០.០០០ នាក់នៅឆ្នាំ២០១១។ ទើបតែពេលថ្មីៗនេះទេ ដែលរដ្ឋាភិបាលបានសង្កត់ធ្ងន់លើគុណភាពឧត្តមសិក្សា និងលក្ខណៈសមស្របទៅនឹងតម្រូវការ។ ក្នុងនេះរដ្ឋាភិបាលផ្តល់មូលនិធិប្រមាណជា ៥០% សម្រាប់ "គម្រោងបង្កើនគុណភាពនិងលើកកម្ពស់សមត្ថភាពឧត្តមសិក្សា" ដែលធនាគារពិភពលោកចូលរួមផ្តល់ជំនួយឲ្យដែរ (Mak 2012)។ គម្រោងនេះមានគោលដៅលើកកម្ពស់សមត្ថភាពគ្រប់គ្រង បង្រៀន និងស្រាវជ្រាវនៃគ្រឹះស្ថានឧត្តមសិក្សាទាំងអស់របស់រដ្ឋនិងឯកជន។ "ក្រុមការងារបច្ចេកទេសផ្នែកឧត្តមសិក្សា" ដែលមានការចូលរួមពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក៏ត្រូវបានបង្កើតឡើងដែរ។

ទី៣ ការផ្តល់សេវាអប់រំជាលក្ខណៈពាណិជ្ជកម្មរបស់គ្រឹះស្ថានឧត្តមសិក្សាឯកជនភាគច្រើន គឺច្រើនតែផ្តោតលើការរកប្រាក់ចំណេញ និងសមត្ថភាពរកចំណូលក្នុងរយៈពេលខ្លី ជាជាងការជួយរួមចំណែកដល់ការអភិវឌ្ឍជាតិក្នុងរយៈពេលវែង (O'Brien 2004)។ គ្រឹះស្ថានឯកជនទាំងនោះ ផ្តល់ការបណ្តុះបណ្តាលជាទ្រង់ទ្រាយតូចដោយសារដើមទុនមានកម្រិតហើយអាចដំណើរការបានដោយពឹងផ្អែកទាំងស្រុងទៅលើការបង់ថ្លៃសិក្សារបស់និស្សិត។ ស្ថានភាពនេះបង្ខំឲ្យគ្រឹះស្ថានឯកជននានា ត្រូវប្រឹងប្រែងទាក់ទាញសិស្សឲ្យចូលសិក្សាក្នុងគ្រឹះស្ថានរបស់ខ្លួន ជាជាងប្រឹងធ្វើការស្រាវជ្រាវនិងបង្រៀនជំនាញដែលសេដ្ឋកិច្ចជាតិត្រូវការ។ ម្យ៉ាងទៀត ប្រាក់ចំណូលមួយភាគធំត្រូវបានចំណាយទៅលើផ្នែករដ្ឋបាល ដែលនាំឲ្យពួកគេមិនអាចពង្រីកកម្មវិធីសិក្សាបានជាពិសេសមុខវិជ្ជាវិទ្យាសាស្ត្រដែលត្រូវចំណាយច្រើន។

បទដ្ឋានធូរលុងក្នុងការចុះឈ្មោះចូលរៀន ដែលផ្តល់សារៈសំខាន់ដល់លទ្ធភាពហិរញ្ញវត្ថុ ច្រើនជាងសមត្ថភាពសិក្សាស្រាវជ្រាវ បានធ្វើឲ្យសិស្សដែលមានលទ្ធភាពបង់ប្រាក់ អាចចូលសិក្សានៅថ្នាក់ឧត្តមសិក្សាបានយ៉ាងងាយស្រួល។ ភាពងាយស្រួលនេះ ធ្វើឲ្យសិស្សបញ្ចប់

តារាង ១. ភាគរយនៃនិស្សិតចុះឈ្មោះចូលរៀនថ្នាក់ឧត្តមសិក្សាផ្នែកវិទ្យាសាស្ត្រ និងភាគរយនៃកម្លាំងពលកម្មមានការបណ្តុះបណ្តាលផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈនៅប្រទេសមួយចំនួនក្នុងតំបន់អាស៊ីអាគ្នេយ៍

| | កម្ពុជា | វៀតណាម | ឥណ្ឌូនេស៊ី | ម៉ាឡេស៊ី | សិង្ហបុរី |
|---|---|---|---|---|---|
| ភាគរយនៃនិស្សិតចុះឈ្មោះ ចូលរៀនថ្នាក់ឧត្តមសិក្សា ផ្នែកវិទ្យាសាស្ត្រនិងវិស្វកម្ម ផលិតកម្មនិងសំណង់ សុខភាពនិងសុខុមាលភាព និងកសិកម្ម | 26.64 | 19.87 (មិនរាប់និស្សិតចុះឈ្មោះចូលរៀនឧត្តមសិក្សាផ្នែកវិទ្យាសាស្ត្រ) | 32.87 | 45.31 | 53.15 |
| ភាគរយនៃកម្លាំងពលកម្មមានការបណ្តុះបណ្តាលផ្នែកបច្ចេកទេស និងវិជ្ជាជីវៈ | 1.1 | 20 | 9.39 | 11.91 | 12.48 |

ប្រភព៖ Un (2012)

វិទ្យាល័យតែងបន្តការរៀនសូត្រនៅថ្នាក់ឧត្តមសិក្សា ជាជាងទៅសិក្សាក្នុងវគ្គអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ដោយសារការបង្រៀនពុំមានគុណភាព និស្សិតបញ្ចប់ការសិក្សាអាចរកការងារធ្វើមិនបានសោះ ឬក៏មិនបានពេញលេញតាមមុខជំនាញរបស់ខ្លួនទេ។

## តើគ្រឹះស្ថានអប់រំនិងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បណ្តុះបណ្តាលអ្វីខ្លះ?

តាំងពីទសវត្សរ៍១៩៩០ មក គោលនយោបាយរបស់រដ្ឋាភិបាលលើការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ បានផ្តោតជានិច្ចលើការកាត់បន្ថយភាពក្រីក្រ តាមរយៈការផ្តល់បំណិនមូលដ្ឋានផ្សេងៗទៅឲ្យប្រជាជនក្រីក្រនៅតំបន់ជនបទ និងជួយទ្រទ្រង់ដល់ការអភិវឌ្ឍសមត្ថភាពបុគ្គលតាមរយៈការផ្តល់ជំនាញ។ ប្រទេសកម្ពុជាផ្តល់អាទិភាពដល់ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈច្រើនជាង ដល់ឧត្តមសិក្សា ដែលអាចពិនិត្យឃើញតាមការចំណាយច្រើនជាងទៅលើនិស្សិតម្នាក់ៗ ក្នុងការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គឺរហូតដល់ ៨០%នៃចំណាយឯកតាសរុប ធៀបនឹងត្រឹម ៦៧%សម្រាប់ឧត្តមសិក្សា (Un 2012)។ អាទិភាពនេះត្រូវបានពង្រឹងឡើងតាំងពីពាក់កណ្តាលទសវត្សរ៍២០០០ មក តាមរយៈការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅឆ្នាំ២០០៥។ ចាប់ពីពេលនោះមក រដ្ឋាភិបាលបានបង្កើនការយកចិត្តទុកដាក់តាមរយៈ ការបង្កើនចំណាយថវិការដ្ឋសម្រាប់ក្រសួងនេះ ចាប់ពី៧៥០.០០០ដុល្លារអាមេរិកក្នុងឆ្នាំ២០០៦ ដល់ ១៣លានដុល្លារអាមេរិកក្នុងឆ្នាំ២០១២ (Un 2012)។ វិស័យឯកជនក៏វិនិយោគយ៉ាងច្រើនលើការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដែរ ប៉ុន្តែគេមិនទាន់រកបានតួលេខជាក់លាក់ទេ។

នៅពេលបច្ចុប្បន្ន ប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈមានវិទ្យាស្ថាន និងសាលាពហុបច្ចេកវិជ្ជាចំនួន ៣៩ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈតាមខេត្តចំនួន ២៥ ដែលផ្តល់នូវកម្មវិធីសិក្សាច្រើនប្រភេទ និងច្រើនកម្រិត ដូចជា ថ្នាក់បរិញ្ញាប័ត្រ ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ នាពេលថ្មីៗនេះ មានគម្រោងចំនួនពីរសម្រាប់ពង្រីកការអប់រំ និងបណ្តុះបណ្តាល បច្ចេកទេសនិងវិជ្ជាជីវៈ គឺមាន "កម្មវិធីសាកល្បងផ្តល់បច្ចេកវិទ្យាក្រោយការប្រមូលផល និងការបំពេញជំនាញសម្រាប់អ្នកក្រីក្រនៅតំបន់ជនបទ" និង "គម្រោងពង្រឹងការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ" ដែលគាំទ្រដោយ ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិប្រទេសជប៉ុនសម្រាប់ការកាត់បន្ថយភាពក្រីក្រ។

ថ្វីបើរដ្ឋាភិបាលបានផ្តល់អាទិភាពដល់ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ហើយការចុះឈ្មោះចូលរៀនរបស់និស្សិតបានកើនឡើងពី ២៧.៨៩៤នាក់ក្នុងឆ្នាំ២០០៥ដល់ ១៦៨.៦៣០នាក់ក្នុងឆ្នាំ២០០៩ (ILO & NIS 2010) ក្តី ក៏កំណើននេះនៅយឺតជាង កំណើនការចុះឈ្មោះចូលរៀននៅឧត្តមសិក្សា។ ប្រទេសកម្ពុជាប្រឈមមុខនឹងឧបសគ្គជាច្រើនក្នុងការពង្រីកការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ទី១ គឺកង្វះមូលនិធិសម្រាប់ទិញសម្ភារៈនិងម៉ាស៊ីនថ្លៃៗ ដែលត្រូវប្រើក្នុងការបណ្តុះបណ្តាល។ ទី២ កិច្ចប្រឹងប្រែងនិងធនធានសម្រាប់ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានលក្ខណៈរប៉ាត់រប៉ាយ ព្រោះអនុវត្តដោយក្រសួង/ស្ថាប័នជាង ១០ ខុសៗគ្នា ដែលមានធនធានហិរញ្ញវត្ថុ និងសមត្ថភាពមនុស្សមានកម្រិត។ ទី៣ កង្វះទុន ការលំបាកនឹងរកបានប្រាក់កម្ចី និងព័ត៌មានទីផ្សារមិនពេញលេញ បានបង្កឧបសគ្គដល់គ្រឹះស្ថានអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងការពង្រីកដែនគ្របដណ្តប់ និងបង្កើនមុខវិជ្ជាបើកបង្រៀន (Knight & MacLeon 2004)។ ទី៤ គ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈទាំងរបស់រដ្ឋ និងឯកជន ភាគច្រើនប្រមូលផ្តុំនៅទីប្រជុំជន ដូច្នេះមិនអាចផ្តល់សេវាទៅឲ្យប្រជាជនភាគច្រើនដែលរស់នៅតាមជនបទនោះទេ។ ទី៥ រដ្ឋាភិបាលមិនទាន់មានគោលនយោបាយនិងយន្តការគាំទ្រ ដើម្បីឲ្យមានតុល្យភាពរវាងគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នឹងគ្រឹះស្ថានឧត្តមសិក្សា នោះទេ។ ឧទាហរណ៍ ក្នុងខេត្តចំនួនពីរដែលមានតំបន់សេដ្ឋកិច្ចពិសេស រដ្ឋាភិបាលបានបង្កើតសាកលវិទ្យាល័យក្នុងខេត្តនីមួយៗ ជាជាងពង្រឹងការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ការវិភាគនៅឆ្នាំ២០០១ លើ ១១ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលជាផ្នែកមួយនៃកម្មវិធីសកម្មភាពអាទិភាព បានបង្ហាញថា ២៧% នៃគ្រឹះស្ថានទាំងនោះមានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ប៉ុន្តែបានទទួលត្រឹមតែ ៩% នៃថវិកាប៉ុណ្ណោះ (Un 2012)។ រដ្ឋាភិបាលមានផែនការបង្កើតឲ្យមានយ៉ាងហោចណាស់វិទ្យាល័យមួយ នៅតាមស្រុកនីមួយៗ ជាជាងបង្កើតមជ្ឈមណ្ឌលអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

## សេចក្តីសន្និដ្ឋាន និងមតិមួយចំនួនផ្នែកគោលនយោបាយ

ទីផ្សារការងារ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចនៅកម្ពុជានាពេលបច្ចុប្បន្នដែលមានទ្រង់ទ្រាយតូចនៅឡើយ គេអាចសំគាល់បានតាមរយៈកំណើនសេដ្ឋកិច្ចយ៉ាងលឿននៅតំបន់ទីក្រុង វិស័យឧស្សាហកម្មប្រើបច្ចេកវិទ្យាកម្រិតទាប វិស័យសេវាកម្មកំពុងរីកដុះដាល តំបន់ជនបទមានការអភិវឌ្ឍតិច និងសេដ្ឋកិច្ចមួយភាគធំផ្អែកលើកសិកម្ម។ មូលដ្ឋានគ្រឹះសេដ្ឋកិច្ចនៅមានលក្ខណៈតូចចង្អៀត ដែលអាចពិនិត្យឃើញតាម ចំនួនភាគរយប្រជាជនដ៏ច្រើនដែលធ្វើការក្នុងវិស័យកសិកម្ម វិស័យឧស្សាហកម្មពឹងផ្អែកធ្ងន់ធ្ងរទៅលើផ្នែកកាត់ដេរនិងសំណង់ ហើយនិង វិស័យសេវាកម្មពឹងផ្អែកទៅលើទេសចរណ៍ និងនាពេលថ្មីៗនេះទៅលើផ្នែកធនាគារផងដែរ។

បច្ចុប្បន្ន នៅពេលសេដ្ឋកិច្ចកម្ពុជាកំពុងចាប់ផ្តើមពង្រីកមូលដ្ឋានគ្រឹះ និងឈានទៅបង្កើនផ្នែកផលិតកម្ម គេឃើញមានតម្រូវការយ៉ាងច្រើននូវធនធានមនុស្សដែលមានជំនាញបច្ចេកទេសនិងឯកទេសខាងវិទ្យាសាស្ត្រដូចជាវិស្វករអ្នកបច្ចេកទេស និងអ្នកឯកទេសខាងកសិកម្មជាដើម។ ទោះយ៉ាងនេះ គ្រឹះស្ថានឧត្តមសិក្សាបណ្តុះបណ្តាលនិស្សិត (ពិសេស ក្នុងមុខវិជ្ជាវិទ្យាសាស្ត្រសង្គម) បានច្រើនជាខ្លាំង លើសពីតម្រូវការទីផ្សារ ហើយនិស្សិតជាច្រើនមានចំណេះដឹង និងជំនាញមិនមានគុណភាព ឬខុសពីតម្រូវការទីផ្សារពលកម្ម។ នៅពេលមានតម្រូវការកាន់តែច្រើនឡើងនូវ ពលករដែលមានជំនាញបច្ចេកទេសនិងវិជ្ជាជីវៈនោះ ខាងគ្រឹះស្ថានអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ មិនអាចបណ្តុះបណ្តាលបានច្រើនគ្រប់គ្រាន់ទេនូវ និស្សិតដែលមានជំនាញស្របតាមតម្រូវការ។

ការពង្រីកប្រកបកំណើនសេដ្ឋកិច្ច ទាមទារឲ្យមានតុល្យភាពកាន់តែប្រសើររវាងឧត្តមសិក្សា នឹងការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ហើយការអប់រំទាំងពីរប្រភេទនេះគួរយកចិត្តទុកដាក់លើមុខវិជ្ជាវិទ្យាសាស្ត្រ និងវិស្វកម្ម។ ក្នុងនេះ គ្រឹះស្ថានឧត្តមសិក្សាត្រូវប្រឹងជំរុញការស្រាវជ្រាវនិងអភិវឌ្ឍ រីឯគ្រឹះស្ថានអប់រំនិងបណ្តុះបណ្តាល

បច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវបណ្តុះបណ្តាលឲ្យបានកាន់តែច្រើន និងមានគុណភាពល្អនូវ និស្សិតដែលមានចំណេះដឹងជំនាញក្នុងវិស័យវិទ្យាសាស្ត្រ។ ម្យ៉ាងទៀតគួរមានជាបន្ទាន់នូវ គោលនយោបាយលើកទឹកចិត្តសិស្សដែលបញ្ចប់ការអប់រំមូលដ្ឋាន ឲ្យចូលទៅសិក្សានៅតាមគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងលើកទឹកចិត្តសិស្សបញ្ចប់វិទ្យាល័យឲ្យជ្រើសរើសមុខវិជ្ជាខាងវិទ្យាសាស្ត្រ។ គួរពង្រីកផងដែរនូវ លទ្ធភាពបានចូលរៀននៅឧត្តមសិក្សា ប៉ុន្តែត្រូវធានាឲ្យមានគុណភាព និងភាពពាក់ព័ន្ធល្អ ដោយពង្រឹងដំណើរការជ្រើសរើសសិស្ស គោលនយោបាយលើមុខវិជ្ជាវិទ្យាសាស្ត្រ បទប្បញ្ញត្តិការសម្របសម្រួលនិងការកសាងសមត្ថភាពស្រាវជ្រាវ។បទពិសោធន៍ធ្វើឧស្សាហូនីយកម្មនៅអាស៊ី បានបង្ហាញពីតម្រូវការពង្រឹងគុណភាពសាកលវិទ្យាល័យ និងគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសាធារណៈ ដើម្បីឲ្យមានគោលដៅច្បាស់លាស់ និងធនធានសម្រាប់អភិវឌ្ឍន៍មូលធនមនុស្សឲ្យមានប្រសិទ្ធភាព។

## ឯកសារយោង


CAMFEBA (2008), Youth and employment: Bridging the gap (Phnom Penh: CAMFEBA)

Chan, S. (2008), “Making the most of Cambodia's human resource”, Cambodia Development Review, 12 (2), pp. 9-11.

D’Amico, S. (2012), “Knowledge and skills needed by the Cambodian economy”, presentation at policy roundtable on Higher Education and Vocational Training in Cambodia, 30 August 2012, Phnom Penh

Heng, S. (2013), “The role of TVET in economic development in Cambodia” (in Khmer), presentation at research workshop on the Role of Vocational Training in Economic Development in Cambodia, 25 January 2013, Phnom Penh

Hing, V., Khieng S., Lun P., Saing C. & L. Strange (2012), “Introduction: Cambodia Outlook—An Overview”, in Annual Development Review 2011-12 (Phnom Penh: Cambodia Development Resource Institute)

HR Inc. Cambodia & Garment Industry Productivity Center (2008), Garment sector salary survey 2007-2008 (Phnom Penh: HR Inc. Cambodia & Garment Industry Productivity Center)

Huot, C. (2013), “Cambodia: Recent economic developments”, presentation at Annual Meeting of Cambodian Economic Association, 26 January 2013, Phnom Penh

ILO & NIS (2010), Labour and Social Trends in Cambodia 2010 (Phnom Penh: National Institute of Statistics)

Knight, K. & K. MacLeon (2004), Integration of teachers’ voices into education for all in Cambodia: Teachers’ status, social dialogue, and the education sector (Phnom Penh: PACT-Cambodia)

Mak, N. (2012), “Cambodian higher education: Challenges, opportunities and future directions”, presentation at policy roundtable on Higher Education and Vocational Training in Cambodia, 30 August 2012, Phnom Penh

Ministry of Planning (MoP) (2013), Poverty in Cambodia – A new approach: Redefining the poverty line (Phnom Penh: MoP)

National Institute of Statistics (NIS) (2008), General population census of Cambodia 2008 (Phnom Penh: Ministry of Planning)

O’Brien, P.N. (2004), “Challenges to higher education in Cambodia: Access, equity of access, and quality and relevance” (Unpublished)

Un, L. (2012), “A comparative study of education and development in Cambodia and Uganda from their civil wars to the present”, Ph.D. thesis (University of Amsterdam)

World Bank (2009), A better investment climate to sustain the growth in Cambodia: Second investment climate assessment (Phnom Penh: World Bank)

World Bank (2012), Cambodia's economic monitor update (July 2012) (Phnom Penh: World Bank)



## អំពីវេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា

វេទិកាសិក្សាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា (DRF) បានកកើតឡើងក្រោយពេលដែល មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) រៀបចំវេទិកាស្ថាប័នដៃគូទាំងអស់មួយ នៅខែកញ្ញា ឆ្នាំ២០០៧។

ទស្សនៈវិស័យរបស់ DRF គឺលើកកម្ពស់សហគមន៍ស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជាឲ្យមានគុណភាពខ្ពស់ និងប្រកបដោយវិជ្ជាជីវៈ ព្រមទាំងមានគោលបំណងទ្រទ្រង់ និងពង្រឹងសមត្ថភាពរបស់សហគមន៍ស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា។

ដៃគូក្នុង DRF មាន វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI), សមាគមសេដ្ឋកិច្ចកម្ពុជា (CEA), វិទ្យាស្ថានសិក្សាស្រាវជ្រាវ និង បណ្តុះបណ្តាល (LI), វិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH), សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA), សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP), ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC), និង មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC)។

ក្នុង DRF ដំណាក់កាលទី២ ដោយបានទទួលជំនួយហិរញ្ញវត្ថុពី IDRC ដៃគូទាំងអស់ធ្វើការយ៉ាងសកម្ម ដើម្បីកសាងវប្បធម៌ស្រាវជ្រាវ និងសមត្ថភាពស្រាវជ្រាវ ព្រមទាំងចែករំលែកចំណេះដឹងគ្នាទៅវិញទៅមកតាមរយៈ សិក្ខាសាលា កិច្ចប្រជុំតុមូល ការបណ្តុះបណ្តាល និងពិភាក្សាតាមអ៊ីនធឺណែត (www.drfcambodia.net) ក្រោម ៦ ប្រធានបទ៖ កំណើនសម្រាប់គ្រប់គ្នា, អភិបាលកិច្ចធនធានធម្មជាតិ, គោលនយោបាយសង្គមកិច្ចស្តីពីការអប់រំ, គោលនយោបាយសង្គមកិច្ចស្តីពីសុខាភិបាល, ការអភិវឌ្ឍកសិកម្ម, និង ប្រទេសកម្ពុជានិងតំបន់ជុំវិញ។

## ក្នុងនាមជាដៃគូនៃ

សមាគមសេដ្ឋកិច្ចកម្ពុជា CAMBODIAN ECONOMIC ASSOCIATION

THE LEARNING INSTITUTE People and Natural Resources

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ Supreme National Economic Council

IDRC | CRDI



## វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)

☞ 56 ផ្លូវ 315, ខណ្ឌទួលគោក ✉ ប្រអប់សំបុត្រលេខ 622, ភ្នំពេញ កម្ពុជា

☏ (855 23) 881 384/881 701/881 916/883 603 🖷 (855 23) 880 734

អ៊ីមែល: cdri@cdri.org.kh, គេហទំព័រ: www.cdri.org.kh